# ការចិញ្ចឹមឃ្មុំស្រុក (Apis cerana)

បណ្ឌិត ជាង ហុង នាយករងផ្នែកស្រាវជ្រាវ និងផ្សព្វផ្សាយ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

## ១. សញ្ញាណ

ប្រទេសកម្ពុជា ជាប្រទេសស្ថិតនៅក្នុងតំបន់ត្រូពិច មានអាកាសធាតុក្តៅសើម ជាលក្ខខណ្ឌសមប្រកបដល់រុក្ខជាតិដុះលូតលាស់។ លក្ខខណ្ឌនេះ មានអំណោយផលដ៏ប្រពៃសម្រាប់ការចិញ្ចឹមឃ្មុំស្រុកឬហៅថាព្រួត *Apis cerana*) ដើម្បីទាញយកផល ជាទឹកឃ្មុំ លម្អងឃ្មុំ ទឹកដោះស្តេច ក្រមួនឃ្មុំ ..ជាពិសេសចិញ្ចឹមឃ្មុំមានប្រសិទ្ធភាពជួយបង្កាត់ពូជខ្វែង ដល់ដំណាំជួយបង្កើន ទិន្នផលដំណាំរហូតដល់ ២០%។



ដើម្បីចិញ្ចឹមឃ្មុំស្រុក (ព្រួត) ឲ្យមានប្រសិទ្ធភាពសេដ្ឋកិច្ចខ្ពស់ ចាំបាច់ត្រូវការយល់ដឹង និងការអនុវត្តន៍ល្អនូវជំហានខាងក្រោមៈ

## ២. ការចិញ្ចឹមឃ្មុំក្នុងគ្រួសារជនបទ

### ២.១. បច្ចេកទេសចិញ្ចឹម

- ចាំបាច់ត្រូវសិក្សាឲ្យច្បាស់លាស់អំពីទ្រឹស្តីនៃការចិញ្ចឹម និងការអនុវត្តផ្ទាល់ឲ្យបានច្រើន
- រក្សាទំនាក់ទំនងជាមួយអ្នកបច្ចេកទេសនៅពេលការចិញ្ចឹមជួបឧបសគ្គ

### ២.២. ជ្រើសរើសពូជន៍ឃ្មុំមកចិញ្ចឹម

- ពូជឃ្មុំអាចចាប់ក្នុងធម្មជាតិ ឬ ទិញពីកសិដ្ឋានចិញ្ចឹមឃ្មុំ
- សំបុកត្រូវមានយ៉ាងតិច ៣បង្គង(៣ផ្ទិត) មានកូនឃ្មុំច្រើនគ្របជិតទាំងសងខាងផ្ទិត
- លើផ្ទិតត្រូវមានពង ដង្កូវឃ្មុំ ដុកដឿដែលបិទគម្របស្មើល្អ
- បង្គងមានពណ៌លឿងមានទឹក និងលម្អងច្រើន
- ស្តេចឃ្មុំធំ វែង រហ័សរហួន មិនពិការ
- ទូទាំងសំបុកឃ្មុំធ្វើការខ្លាំង គ្មានជំងឺ

## ៣. ត្រៀមសំបុកឃ្មុំសម្រាប់រដូវប្រមូលផល

ដើម្បីប្រមូលបានទិន្នផលខ្ពស់ សំបុកឃ្មុំត្រូវមានឃ្មុំ កម្មករច្រើន (ប្រមាណ២០០ក្រាម/ផ្ទិត) ស្តេចល្អ គ្មានជំងឺ គ្មានការចែកសំបុកធម្មជាតិ។ ដូច្នេះត្រូវៈ

– ជំរុញឲ្យឃ្មុំសង់ផ្ទិតថ្មី ដើម្បីបន្ថែមកន្លែងផ្ទុកពង និង ផ្ទុកទឹកឃ្មុំ

– មុនរដូវផ្ការីកត្រូវឲ្យចំណី៣ ទៅ៤ ដង(ទឹកស្ករអត្រា១:១) ដើម្បីរំញោចឲ្យស្តេចពងច្រើន និងឃ្មុំកម្មករធ្វើការខ្លាំង

– ដកផ្ទិតខ្លះពីសំបុកដែលមានផ្ទិតច្រើន ឃ្មុំខ្លាំង គ្មានជំងឺ មកបន្ថែមឲ្យសំបុកខ្សោយ

## ៤. ការបង្កើតស្តេចល្អសម្រាប់ហ្វូងឃ្មុំ

ដើម្បីបានស្តេចឃ្មុំល្អ ត្រូវបង្កើតស្តេចពីសំបុកដែលមានទិន្នផលខ្ពស់ ខ្លាំង មានកូនច្រើន គ្មានជំងឺស្លូត មិនស្ទូវ ឬគ្មានចរិកលក្ខណៈចែកសំបុកធម្មជាតិ

ប្រើប្រាស់កំពែងស្តេចដែលបង្កើតដោយធម្មជាតិពីសំបុក ខ្លាំង ដាក់ជំនួសស្តេចក្នុងសំបុកខ្សោយ

បង្កើតស្តេចសិប្បនិម្មិតៈ ផ្តាច់ស្តេចពីសំបុកពូជ ដើម្បីជំរុញឲ្យឃ្មុំបង្កើតស្តេចបន្ទាន់។ ២ថ្ងៃក្រោយមកបិះផ្តាច់ចោលបណ្តាកំពែងស្តេចលើផ្ទិតទុកតែកំពែងណាដែលនៅខាងក្រោមផ្ទិត ហើយវែងត្រង់ល្អ។

បង្កើតស្តេចពីពងៈ ផ្តាច់ស្តេចពីសំបុកសម្រាប់

ធ្វើពូជចេញ ចាំរយៈពេល២៤ម៉ោងក្រោយ ទើបដាក់ចូលសំបុកឃ្មុំនូវបង្គងដែលបានភ្ជាប់កំពែងស្តេចដែលបានផ្តិះភ្ជាប់នូវដង្កូវឃ្មុំ អាយុ១ថ្ងៃក្រោយញាស់។ ក្រោយពី៩ ទៅ១០ ថ្ងៃត្រូវជ្រើសរើសស្តេចទៅប្រើប្រាស់។ ១០ ទៅ ១៥ថ្ងៃ ក្រោយស្តេចនឹងចាប់ផ្តើមពង។ គួរដូរស្តេចថ្មីក្នុងរយៈពេល៦ ទៅ៩ ខែម្តង។



## ៥. ការបំបែកសំបុក

– បំបែកសំបុកនៅនឹងកន្លែង : បំបែកចំនួនបង្គងឃ្មុំជាពីរផ្នែកដោយដាក់ចូលក្នុងធុងពីរផ្សេងគ្នា។ ដំបូងទិស បណ្តោយធុងត្រូវដាក់ស្របគ្នា ក្រោយមកបន្តិចម្តងៗលើក សំបុកឃ្លាតពីគ្នាហើយបង្វិលទិសឲ្យផ្ទុយពីគ្នា។ ពេលផ្តាច់ បង្គងពីគ្នា ត្រូវលៃស្មើគ្នានូវកូនឃ្មុំ ពងឃ្មុំ និងចំណីគួរបន្ថែមស្តេចសម្រាប់សំបុកដែលគ្មានស្តេច។

– បំបែកសំបុកផ្លាស់ទី : ផ្តាច់សំបុកដូចខាងលើតែត្រូវយកធុងមួយដាក់ឲ្យឆ្ងាយពីធុងមួយទៀតយ៉ាងតិច១,៥ គ.ម ។ ដាក់ស្តេចសិប្បនិម្មិតចូល។

## ៦. ជ្រើសទីតាំងសម្រាប់ដាក់ចិញ្ចឹមឃ្មុំ

– ដាក់ក្បែរប្រភពទឹកដមផ្កា និងលំអងទីស្ងប់ស្ងាត់ មានម្លប់ត្រជាក់ ឆ្ងាយពីបឹងធំៗ និងត្រូវប្រយ័ត្នសត្រូវឃ្មុំដូចជា គីងគក់ ស្រមោច ជីងចក់ ...។

## ៧. ការពារឃ្មុំហើរចាកចោលសំបុក

– ដោះស្រាយទាន់ពេលនូវបញ្ហាខាងក្រោម: ខ្វះចំណី ជំងឺនិងសត្រូវយាយី ផ្លិតឃ្មុំចាស់ពេកទីតាំងដាក់ឃ្មុំមិនល្អ ដូចជាទីក្តៅ មានសម្លេងអ៊ូអរ មានមនុស្សដើរកាត់ច្រើន...។







